ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
26 / 09 / 2016
ម៉ោង (Time/Heure) : 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN KADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

## ថ្ងៃ ព្រហស្បតិ៍ ទី ២៥ ខែ សីហា ឆ្នាំ ២០១៦

## សវនាការលើភស្តុតាង - ថ្ងៃ ៤៤៥

រៀបចំដោយ៖ កញ្ញា ជា ស៊ីវហ៊ង និង លោក Roger PHILLIPS

| កំណត់ហេតុអ្នកចូលរួម |
|---|
| ចំពោះមុខ ចៅក្រម យ៉ា សុខន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា, ចៅក្រម Claudia FENZ, ចៅក្រម ធូ មណី |
| ចៅក្រមបំរុង៖ ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី ៖ កញ្ញា ជា ស៊ីវហ៊ង និង លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង លាង, លោក Vincent de Wilde d'Estmael, លោក ស្រ៊ា រតនៈ, លោក Travis FARR និង លោក Cóman KENNY |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក លីវ សុវណ្ណា, លោកស្រី Doreen CHEN |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោកស្រី Anta GUISSÉ, លោក គង់ សំអុន |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោក ពេជ អង្គ, លោកស្រី Marie GUIRAUD, លោក ហុង |

| |
|---|
| គឹមសួន, លោក វ៉ែន ពៅ, លោកស្រី ស៊ីន សុវ៉ិន, លោកស្រី ជេត វណ្ណលី |
| ដើមបណ្ដឹង/សាក្សី/អ្នកជំនាញ៖ យស ផល (2-TCCP-232) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ និង លោកស្រី សួ សុធារី |
| ផ្សេងៗ៖ លោក កែវ វ៉ាត, កញ្ញា ស្រី ណាក់, លោក ឡាយ ណារ៉ា, លោកស្រី ពេជ ចរិយា, កញ្ញា Aureliarita MARCELLUS |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ | ចាប់ផ្តើមម៉ោង៖ ០៩.០៤ | បញ្ចប់ម៉ោង៖ ១៤.១២ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.១០ | បញ្ចប់ម៉ោង៖ ១០.៣៤ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ ១១.៣៣ | បញ្ចប់ម៉ោង៖ ១៣.៣៣ |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ២ ម៉ោង ៤៦ នាទី |

**កិច្ចដំណើរការនីតិវិធីផ្សេងទៀត**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៥ | ០៩.១០ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.០៨ | ០៩.០៩ |
| សារណាផ្ទាល់មាត់ពាក់ព័ន្ធនឹងឯកសារវៀតណាម | មេធាវីការពារក្តី ខៀវ សំផន<br>សហព្រះរាជអាជ្ញា<br>សហមេធាវីនាំមុខ<br>មេធាវីការពារក្តី នួន ជា | ០៩.១១<br>០៩.១៣<br>០៩.១៦<br>០៩.១៧ | ០៩.១៣<br>០៩.១៦<br>០៩.១៧<br>០៩.១៨ |
| ការតាំងសំណួរទៅកាន់ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល (2-TCCP-232) | អង្គជំនុំជម្រះ<br>សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី<br>សហព្រះរាជអាជ្ញារង | ០៩.១៩<br>០៩.២៥<br>១០.៥៨ | ០៩.២៥<br>១០.៥៧<br>១១.៣២ |
| សារណាផ្ទាល់មាត់ពាក់ព័ន្ធនឹងការប្រើប្រាស់របស្សនាម និងវិធានការការពារ | សហព្រះរាជអាជ្ញា | ១៣.៣៤<br>១៣.៤២ | ១៣.៣៥<br>១៣.៤៥ |

| | | | |
|---|---|---|---|
| | | ១៣.៤៦ | ១៣.៤៧ |
| | សហមេធាវីនាំមុខ | ១៣.៣៦ | ១៣.៣៨ |
| | មេធាវីការពារក្ដី នួន ជា | ១៣.៣៨ | ១៣.៣៨ |
| | មេធាវីការពារក្ដី ខៀវ សំផន | ១៣.៣៨ | ១៣.៣៨ |
| | អង្គជំនុំជម្រះ | ១៣.៤១ | ១៣.៤២ |
| | | ១៣.៤៥ | ១៣.៤៦ |

**សេចក្ដីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖**

**ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការនិងការប្រកាសពីវត្តមានរបស់ភាគី**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថា គ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។

**សំណើរបស់ នួន ជា សុំតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីដោយផ្ទាល់ក្នុងសាលសវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីសវនាការពីបន្ទប់ឃុំខ្លួនស្ថិតនៅខាងក្រោមសាលសវនាការ។

**សារណាផ្ទាល់មាត់ពាក់ព័ន្ធនឹងឯកសារវៀតណាម**

មេធាវីការពារក្ដី ខៀវ សំផន បានលើកឡើងអំពីកាលបរិច្ឆេទកំណត់សំរាប់ក្រុមមេធាវីការពារក្ដីក្នុងការធ្វើការកត់សម្គាល់ទៅលើការទទួលយកឯកសារវៀតណាម (E327/4/5) ហើយថាការកំណត់ត្រឹមថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ គឺមិនអាចធ្វើបានទេ។ ដូច្នេះ មេធាវីការពារក្ដី ខៀវ សំផន បានស្នើឱ្យអង្គជំនុំជម្រះពន្យារពេលកំណត់។

សហព្រះរាជអាជ្ញាផ្អែកទៅតាមសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះពាក់ព័ន្ធនឹងការកំណត់កាលបរិច្ឆេទនេះ។ បន្ថែមពីលើនេះទៀត សហព្រះរាជអាជ្ញាបានស្នើឱ្យអង្គជំនុំជម្រះត្រួតពិនិត្យមើលទៅលើតារាងដែលបង្ហាញពីឯកសារផ្សេងៗនៃឧបសម្ព័ន្ធ ដោយសារតែមានឯកសារខ្លះគឺមិនស៊ីសង្វាក់គ្នាជាមួយនឹងឯកសារដែលបានភ្ជាប់ជូនទេ ជាពិសេសគឺឯកសារ E327/4/5.1។

មេធាវីការពារក្ដី នួន ជា បានបញ្ជាក់បន្ថែមពីភាពដែលមិនអាចធ្វើទៅបានក្នុងការដាក់ចម្លើយតបទៅតាមពេលវេលាកំណត់របស់អង្គជំនុំជម្រះ។

ពាក់ព័ន្ធនឹងសំណើរបស់មេធាវីការពារក្ដី ខៀវ សំផន ទាក់ទងនឹង E327/4/5 អង្គជំនុំជម្រះបញ្ជាក់ថាខ្លួន

អាចនឹងសម្រេចទទួលយកឯកសារខ្លះ ឬ ឯកសារទាំងអស់ដែលមាននៅក្នុងអនុស្សរណៈ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ។ អង្គជំនុំជម្រះអនុញ្ញាតិតាមសំណើរបស់មេធាវីការពារក្តី ខៀវ សំផន ក្នុងការពន្យាពេលកំណត់នេះ។ ភាគីទាំងអស់ត្រូវដាក់ចម្លើយតបរបស់ខ្លួនទៅលើភាពទទួលយកបាននៃឯកសារដែលមាននៅក្នុងអនុស្សរណៈ ឲ្យបានត្រឹមថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១៦។ អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចទៅលើសំណើដែលនៅសេសសល់ក្នុងពេលសមស្របខាងមុខ។

<u>ការតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល (2-TCCP-232)</u>

អង្គជំនុំជម្រះ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា បានតាំងសំណួរទៅកាន់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល (2-TCCP-232)។

<u>សារណាផ្ទាល់មាត់ពាក់ព័ន្ធនឹងការប្រើ ប្រាស់រហស្សនាម និងវិធានការការពារ</u>

សហព្រះរាជអាជ្ញាបានលើកឡើងថា មិនមានសំអាងហេតុណាមួយសម្រាប់ការស្តាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះដោយប្រើប្រាស់តែរហស្សនាមរបស់គាត់នោះឡើយ។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមិនបានបដិសេធ ឬ ស្នើសុំវិធានការការពារសម្រាប់ភាពឯកជន ឬ សុវត្ថិភាពរបស់គាត់នោះទេ។ សហមេធាវីនាំមុខ បានបញ្ជាក់ថាដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមិនមានបញ្ហានោះទេ ក្នុងការបង្ហាញអត្តសញ្ញាណរបស់គាត់។ មេធាវីការពារក្តី នួន ជា បានលើកឡើងថាជាគោលការណ៍ទូទៅ កិច្ចដំណើការនីតិវិធីគួរត្រូវធ្វើឡើងជាសាធារណៈ។ មេធាវីការពារក្តី ខៀវ សំផន បានលើកឡើងអំពីភាពចាំបាច់ក្នុងការទទួលបានការកាត់ក្តីដោយយុត្តិធម៌ និងការស្វែងរកការពិត។
(ក្រោយមក អង្គជំនុំជម្រះបានទទួលដំណឹងថា សហចៅក្រមស៊ើបអង្កេតបានដកសេចក្តីបង្គាប់របស់ខ្លួនក្នុងការឲ្យប្រើប្រាស់តែរហស្សនាមរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះហើយ (ឯកសារ D193/96))។

## Reclassified Document

| *TC No* | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E319/35 | | 01188632-01188635 01167284-01167286 01175045-01175047 | Memo from the OCIJ entitled "Disclosure of materials from case 003 & 004 to case 002" | P | / | / | / |
| E3/5733 | | 00411854-00411860 00850849-00850854 00942171-00942174 | Civil party application of Mr. YOS Phal | P | 00411856 - 00411857 | 00850851 | 00942172 |

## Other Documents

| *TC No* | OCIJ No | ERN (KH, ENG, FR) | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E319/7 | | 01049267-01049276 01049260-01049266 01072314-01072322 | Decision on OCP request to admit documents relevant to Tram Ok Cooperatives and Kraing Ta Chan Security Centre and order to use of written record of interview from case file 003 and 004. | P | / | / | / |
| E3/4611 | | 00418482-00418489 00455374-00455380 00455381-00455389 | Written Record of Interview of Civil Party YOS Phal [illegible] | P | 00418487 | 00455379 | 00455386 |
| E3/4612 | | 00580746-00580748 00861858-00861859 00938428-00938429 | Supplementary information of civil party applicant | P | 00580747 | 00861858 | 00938428 |

| ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖ |
|---|
| • អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរការនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ ហើយបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ។ (០៩.០៨)<br>• បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ទៅកាន់មន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនពួកគាត់ត្រឡប់មកកាន់សាលសវនាការវិញឱ្យបានមុនម៉ោង ៩.00 ព្រឹក នៅថ្ងៃ ច័ន្ទ ទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ។ (១៤.១២) |

| កាលវេលាសវនាការបន្ត |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ចាប់ផ្តើមពីម៉ោង ០៩.00 ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦

ក្រឡាបញ្ជី ក្រឡាបញ្ជី

កញ្ញា ជា ស៊ុំ... Roger PHILLIPS